# អតិផរណាកម្ពុជាប្រចាំខែមេសា ឆ្នាំ២០១១

## I- ស្ថានភាពសេដ្ឋកិច្ចសកលលោក និងជំហរគោលនយោបាយរូបិយវត្ថុ

### ក/- ស្ថានភាពទូទៅនៃសេដ្ឋកិច្ចសកលលោក







រហូតមកដល់ឆមាសទី១ ឆ្នាំ២០១១ នេះ ការងើបឡើងនៃសេដ្ឋកិច្ចពិភពលោកបាននិងកំពុងតែបន្តល្បឿនឆ្ពោះទៅមុខជានិច្ច ប៉ុន្តែនៅមានបញ្ហាប្រឈមមួយចំនួនដូចជា អត្រានិកម្មភាពនៅមានកម្រិតខ្ពស់ កំណើនសេដ្ឋកិច្ចនៅមានកម្រិតទាប ជាពិសេស សេដ្ឋកិច្ចនៃប្រទេសអភិវឌ្ឍន៍មានបញ្ហាបំណុលសាធារណៈ ។ តាមការព្យាករណ៍របស់ IMF នៅឆ្នាំ២០១១ នេះ សេដ្ឋកិច្ចពិភពលោកត្រូវបានរំពឹងថា នឹងមានកំណើន ៤,៤% ទាបជាងកំណើន ឆ្នាំ ២០១០ ដែលមានកំណើន ៥,៥% ។ ចំណែកសេដ្ឋកិច្ចប្រទេសជប៉ុន នឹងថយចុះ យ៉ាងខ្លាំងពី ៣,៩% នៅឆ្នាំ២០១០ មក ១,៤% នៅឆ្នាំ២០១១ នេះ ដោយសារគ្រោះធម្មជាតិនៃការរញ្ជួយដី និងរលកយក្សស៊ូណាមី ។ ចំពោះទំហំពាណិជ្ជកម្មពិភពលោកវិញ ត្រូវបានរំពឹងថានឹងមានកំណើន ៧,៤% ទាបជាងកំណើនក្នុងឆ្នាំ២០១០ ដែលមានទំហំរហូតដល់ ១២,៤% ។ ប្រទេសអភិវឌ្ឍន៍ត្រូវបានរំពឹងថានឹងមានកំណើនសេដ្ឋកិច្ច ២,៤% អត្រាអតិផរណា ២,២% អត្រានិកម្មភាព ៧,៨% និងគណនីចរន្តមានឱនភាព ០,៣% នៅក្នុងឆ្នាំ២០១១ នេះ ។ ចំណែកឯស្ថានភាពសេដ្ឋកិច្ចនៃប្រទេសកំពុងអភិវឌ្ឍន៍វិញ រំពឹងថានឹងមាន កំណើន ៦,៥% ក្នុងនោះកំណើនសេដ្ឋកិច្ចប្រទេសចិន ឥណ្ឌា និងអាស៊ាន-៥ នឹងថយចុះបន្តិចពី ១០,៣% ១០,៤% និង ៥,៤% នៅក្នុងឆ្នាំ២០១០ មកត្រឹម ៩,៦% ៨,២% និង ៥,៤% រៀងគ្នាក្នុងឆ្នាំ២០១១ នេះ[1] ។

### ខ/- ស្ថានភាពអតិផរណានិងជំហរគោលនយោបាយរូបិយវត្ថុ

#### ១. ស្ថានភាពអតិផរណា

---

[1] World Economic Outlook, April 2011

បច្ចុប្បន្ននេះ ថ្លៃទំនិញបានចាប់ផ្តើមកើនឡើងវិញយ៉ាងឆាប់រហ័ស ដែលបង្កឱ្យអតិផរណាបានកើនឡើងជាបន្តបន្ទាប់ ។ អត្រាអតិផរណារបស់ប្រទេសអភិវឌ្ឍន៍កំពុងមាននិន្នាការកើនឡើងជាបន្តបន្ទាប់ នៅសហរដ្ឋ-អាមេរិក អតិផរណាបាននិងកំពុងកើនឡើង ពី ១,៥% នៅដំណាច់ឆ្នាំ២០១០ ទៅ២,៧% នៅខែមីនា និងទៅដល់ ៣,២% នៅខែមេសា ឆ្នាំ២០១១ ខណៈដែល នៅសហគមន៍ អឺរ៉ុប អតិផរណាក៏បាននិងកំពុងកើនឡើងផងដែរ គឺពី ២,២% នៅដំណាច់ឆ្នាំ២០១០ ដល់ ២,៧% នៅខែមីនា និងទៅដល់ ២,៨% នៅខែមេសា ឆ្នាំ២០១១ ។ អតិផរណា ប្រទេសអង់គ្លេសវិញមានកម្រិតខ្ពស់ជាងបណ្តាប្រទេសអភិវឌ្ឍន៍ផ្សេងៗទៀត បានឡើងចុះៗក្នុងរយៈពេល ៤ខែដើមឆ្នាំ២០១១ នេះ ។ អត្រានេះបានឡើងរហូតដល់ ៤,៥% ក្នុងខែមេសា ឆ្នាំ២០១១ បន្ទាប់ពីបានធ្លាក់ចុះដល់ ៤% នៅខែមីនាឆ្នាំដដែលនេះ ។




ចំណែកអត្រាអតិផរណាអាស៊ីវិញក៏បាននិង កំពុងកើនឡើងគួរឱ្យព្រួយបារម្ភផងដែរ ។ ប្រទេសសមាជិកអាស៊ាន ដូចជាប្រទេសវៀតណាមបានកើនឡើងយ៉ាងលឿន ពី ១១,៧៥% នៅដំណាច់ឆ្នាំ២០១០ រហូតដល់ ១៧,៥% ខែមេសា ឆ្នាំ២០១១ ដែលជាអត្រាមួយខ្ពស់បំផុតក្នុងរយៈពេល២៧ខែចុងក្រោយនេះ ខណៈដែល អតិផរណានៅ ប្រទេសថៃបានកើនឡើងក្នុងល្បឿនយឺតៗ ពី ៣,០៤% នៅដំណាច់ឆ្នាំ២០១០ មក ៤,០៤% នៅខែឧសភា ឆ្នាំ២០១១ បន្ទាប់ពីបានធ្លាក់ចុះ បន្តិចក្នុងខែកុម្ភៈ ។




នៅប្រទេសចិន អតិផរណាបានកើនឡើងជាបន្តបន្ទាប់ពី ៤,៦% នៅដំណាច់ឆ្នាំ២០១០ ទៅ ៥,៤% នៅខែមីនា ឆ្នាំ២០១១ ខណៈដែលអតិផរណានៅឥណ្ឌាបានធ្លាក់ចុះសន្សឹមៗពី ៩,៥% នៅដំណាច់ឆ្នាំ២០១០ មក ៨,៨% នៅខែមីនា ឆ្នាំ២០១១នេះ ។

មូលហេតុចម្បងដែលបណ្តាលឱ្យមានកំណើនអត្រាអតិផរណានៅលើសកលលោកគឺដោយសារ (១)- ការកើនឡើងថ្លៃប្រេងនៅលើទីផ្សារអន្តរជាតិ ដែលបណ្តាលមកពីភាពវឹកវរនៅពិភពអារ៉ាប់ និងអាហ្វ្រិក ខាងជើង និងតម្រូវការប្រេងលើទីផ្សារពិភពលោក បន្ទាប់ពីសេដ្ឋកិច្ចសកលលោកបានងើបឡើងវិញ (២)- កំណើននៃថ្លៃម្ហូបអាហារ ដឹកជញ្ជូន ផ្ទះសម្បែង និងការខូចខាតផលិតផលកសិកម្មនៅចុងឆ្នាំ២០១០ ដោយសារគ្រោះ

ធម្មជាតិ (៣)- កំណើនឥណទានយ៉ាងលើសលប់ក្នុងការស្តារសេដ្ឋកិច្ច និង (៤)- បញ្ហាអស្ថិរភាពនយោបាយ រយៈពេលវែងនៅក្នុងតំបន់ ។

### ២. ជំហរគោលនយោបាយរូបិយវត្ថុនៃប្រទេសអភិវឌ្ឍន៍និងតំបន់អាស៊ី

ឆ្លើយតបចំពោះបញ្ហាប្រឈមនេះ ធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍន៍ ដូចជា ជប៉ុននិងសហរដ្ឋ-អាមេរិក នៅតែបន្តអនុវត្តគោលនយោបាយរូបិយវត្ថុពង្រីករបស់ខ្លួន ជាក់ស្តែង ធនាគារកណ្តាលអាមេរិកបានរក្សាអត្រាគោលត្រឹមកម្រិត ០,២៥% ចាប់តាំងពីដើមឆ្នាំ២០០៩ មក ក្នុងគោលដៅគាំទ្រកំណើនសេដ្ឋកិច្ច និងដោះស្រាយបញ្ហានិកម្មភាពខ្ពស់ក្រោយវិបត្តិសេដ្ឋកិច្ច ។

ធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍន៍មួយចំនួនទៀត បានចាប់ផ្តើមអនុវត្តគោលនយោបាយរូបិយវត្ថុរឹតត្បិត ដើម្បីឆ្លើយតបទៅនឹងនិន្នាការកើនឡើងនៃអតិផរណា នៅក្នុងប្រទេសទាំងនោះ ។ ជាក់ស្តែង ធនាគារកណ្តាល សហគមន៍អឺរ៉ុប បានតម្លើងអត្រាគោលរបស់ខ្លួនពី១% មក ១,២៥% នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១១ ខណៈដែលប្រទេសអូស្ត្រាលីនៅរក្សាអត្រាគោលត្រឹម ៤,៧៥% ដដែល ចាប់ពីខែវិច្ឆិកា បន្ទាប់ពីតម្លើងពី ៤,៥០% ក្នុងខែតុលា ឆ្នាំ ២០១០ ។




ចំណែកឯប្រទេសអាស៊ីនិងសមាគមន៍អាស៊ានមួយចំនួនបានចាប់ផ្តើមអនុវត្តគោលនយោបាយរូបិយវត្ថុរឹតត្បិតជាបន្តបន្ទាប់ ដោយបានបង្កើនអត្រាគោលរបស់ គេ ដូចជា ធនាគារកណ្តាល ប្រទេសវៀតណាម បានបង្កើនអត្រាគោលរបស់គេជាបន្តបន្ទាប់ពី ៦% នៅខែកញ្ញា ឆ្នាំ២០១០ និងទៅ ១៣% នៅខែឧសភា ឆ្នាំ២០១១ ខណៈប្រទេសចិនក៏បានបង្កើនអត្រាគោល ចំនួន ៥ដង ចាប់តាំងពីខែកញ្ញា ឆ្នាំ ២០១០ រហូត ដល់ខែមេសា ឆ្នាំ២០១១ គឺ ពី ៥,៣១% ទៅដល់ ៦,៣១% ។




## II - ស្ថានភាពសេដ្ឋកិច្ចនិងធនាគារនៅកម្ពុជា

## ក/- កំណើនសេដ្ឋកិច្ច

ខណៈដែលសេដ្ឋកិច្ចសកលលោកកំពុងបន្តងើបឡើង សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងកើនក្នុងកម្រិត ៦% នៅក្នុងឆ្នាំ២០១១ នេះ ធៀបនឹងឆ្នាំ២០១០ មានកម្រិត ៥,៩% ។ កំណើនសេដ្ឋកិច្ចនេះ ដោយសារភាពអំណោយផល ពីវិស័យទេសចរណ៍ ការនាំចេញ វិនិយោគផ្ទាល់បរទេស និងវិស័យកសិកម្ម ។ ទិន្នន័យថ្មីៗ បានបង្ហាញថា កំណើនឆ្នាំលើឆ្នាំនៃការនាំចេញ បានកើនឡើង ៤៤,៣% ការនាំចូល ៣០% និងចំនួនភ្ញៀវទេសចរ ១៣,៩% ក្នុងត្រីមាសទី១ ឆ្នាំ២០១១ នេះ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១០ ។

## ខ/- ការនាំចេញនិងការនាំចូល

នៅត្រីមាសទី១ ឆ្នាំ២០១១ នេះ ១/- ការនាំចេញមានចំនួន ៩៦៨,២៤ លានដុល្លារអាមេរិក ដែលមានកំណើន ៣៩,២៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០១០ ដែលក្នុងនោះការនាំចេញសំលៀកបំពាក់បានរួមចំណែករហូតដល់ ៨៣% នៃការនាំចេញសរុប ។ ២/- ការនាំចូលមានចំនួន ១៣៤៨,៥៧ លានដុល្លារអាមេរិក និងមានកំណើន ២៥,៤៣% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០១០ ។ ជាតុសំខាន់ដែលនាំឱ្យមានកំណើនក្នុងការនាំចូលសរុប រួមមានក្រណាត់ ២៥% ប្រេង ១១% និងជាតុដទៃទៀត ៦៤% (ដូចជា បារី ម៉ូតូ រថយន្ត ស៊ីម៉ង់ ដែក...។ល។) ។













## គ/- វិនិយោគផ្ទាល់បរទេស

វិនិយោគផ្ទាល់បរទេសសរុបនៅក្នុងឆ្នាំ២០១០ មាន ចំនួន ៥.៩៥៨,៤ លានដុល្លារអាមេរិក និងមានកំណើន ១៥,១២% ធៀបនឹង ឆ្នាំ២០០៩ ។ នៅក្នុងឆ្នាំ២០១០ វិនិយោគផ្ទាល់បរទេសរបស់ចិន និងម៉ាឡេស៊ីមាន ចំណែកដូចគ្នាគឺ ១៥% កូរ៉េ ១១% សឹង្ហបូរី ៥% តៃវ៉ាន់ ៨% ថៃ ៧% និង វៀតណាម ៨% នៃការវិនិយោគ សរុប ។ រីឯវិនិយោគផ្ទាល់បរទេសតាមវិស័យបានបង្ហាញថា ការវិនិយោគលើវិស័យធនាគារ ២២% សំលៀកបំពាក់ ១៨% និងវិស័យកសិកម្ម ១១% នៃការវិនិយោគ ផ្ទាល់បរទេសនៅក្នុងប្រទេសកម្ពុជា ។



Figure11 : Foreign Dirct Investment



Figure12: Share of FDI in 2010



Figure 13: Share of FDI in 2010

## ឃ/- ស្ថានភាពអត្រាប្តូរប្រាក់

ក្នុងរយៈពេល ៤ខែចុងក្រោយនេះ ប្រាក់រៀលបានឡើងថ្លៃធៀបនឹងប្រាក់ដុល្លារ ប្រមាណ 0,៨% និង ៤,៣% នៅខែមេសា ឆ្នាំ២០១១ ធៀបនឹងខែធ្នូ និងខែដូចគ្នាឆ្នាំ២០១០ ។ ការឡើងថ្លៃប្រាក់រៀលនេះ គឺបណ្តាលមកពីការកើនឡើងនៃតម្រូវការប្រាក់រៀល សម្រាប់ទិញកសិផលនៅរដូវច្រូតកាត់ និងការបង់ពន្ធជូនរដ្ឋ ការថយចុះតម្លៃនៃប្រាក់ដុល្លារ និងកត្តាគួបផ្សំមួយចំនួនទៀត ដូចជា ការបង្កើតសេវាទូទាត់ជាប្រាក់រៀលតាមម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិរបស់ប្រព័ន្ធធនាគារ ក៏ជាកត្តាដែលនាំឱ្យតម្រូវការប្រាក់រៀលកើន

Figure 14: Currencies Againt Cambodian Riel
Index: End-Dec 2009=100



ឡើងដែរ ។

ប្រាក់រៀលបើធៀបជាមួយនឹងរូបិយប័ណ្ណនៃបណ្តាប្រទេសជាដៃគូពាណិជ្ជកម្មមួយចំនួន បានចុះថ្លៃ ៣,១% ធៀបនឹងប្រាក់រីងហ្គីត ៦,៨% ធៀបនឹងប្រាក់ដុល្លារសឹង្ហបូរី ១០,២% ធៀបនឹងប្រាក់យ៉េនជប៉ុន ៣% ធៀបនឹងប្រាក់បាតថៃ និង ០,៥% ធៀបនឹងប្រាក់យ័ន់ចិន ប៉ុន្តែបានឡើងថ្លៃ ១១,៣% ធៀបនឹងប្រាក់ដុងវៀតណាមនៅខែមេសា ឆ្នាំ២០១១ ធៀបនឹងខែដូចគ្នាឆ្នាំ២០១០ ។

### ង/- ចលនាអត្រាការប្រាក់




ប្រាក់បញ្ញើជាប្រាក់ដុល្លារក្នុងប្រព័ន្ធធនាគារមានរហូតដល់ទៅ ៩៧% គិតត្រឹមខែមេសា ឆ្នាំ២០១១ ។ ផ្អែកតាមអត្រាការប្រាក់ថ្លឹងរយៈពេល៦ខែ ធនាគារបានកាត់បន្ថយអត្រាការប្រាក់បញ្ញើជាដុល្លារ ជាបន្តបន្ទាប់ពី ៤,៣% នៅដំណាច់ឆ្នាំ២០០៩ មក ៣,៤% នៅខែមេសា ឆ្នាំ២០១១ ។ ទន្ទឹមពេលជាមួយគ្នាដែរ ធនាគារក៏បានកាត់បន្ថយអត្រាការប្រាក់កម្ចីជាប្រាក់ដុល្លាររហូតដល់ ១៧,៤% នៅក្នុងខែមេសា ឆ្នាំ២០១១ បន្ទាប់ពីបានដំឡើងដល់ ១៨,៩% នៅខែធ្នូ ឆ្នាំ២០១០ ។

## III- ស្ថានភាពអតិផរណារបស់កម្ពុជានាខែមេសា ឆ្នាំ២០១១

### ក/- ស្ថានភាពអតិផរណា

### ១- អតិផរណាប្រចាំខែ




អតិផរណាខែលើខែ ក្នុងខែមេសានេះបានកើនដល់ ១,១% ។ នេះជាអត្រាកំណើនខ្ពស់ជាងគេក្នុងអំឡុង ៤ខែ ដើមឆ្នាំនេះ បន្ទាប់ពីមានកំណើនត្រឹម ០,៧% ដូចគ្នានៅខែ កុម្ភៈនិងខែមីនាកន្លងមក (រូប ១៨) ។ អត្រាប្រចាំខែនៅខែមេសា រវាងឆ្នាំ២០១១ និង ២០១០ មាននិន្នាការផ្ទុយគ្នាពោលគឺ អត្រាអតិផរណា ខែមេសា ឆ្នាំ២០១១ មានការកើនឡើងខ្ពស់ដល់ ១,១% ប៉ុន្តែអត្រាអតិផរណាខែមេសា ឆ្នាំ២០១០ បានធ្លាក់ចុះដល់កម្រិតអវិជ្ជមាន -០,៣% ។ ការកើនឡើង នេះអាចឆ្លុះបញ្ជាំងតាមរយៈ (១)- កំណើននៃតម្រូវ ការប្រើប្រាស់ ក្នុងស្រុក ក្នុងឆ្នាំ២០១១ នេះ



ខណៈដែលសេដ្ឋកិច្ចកម្ពុជារំពឹងថានឹងមានកំណើនប្រមាណ ៦% (២)-ការឡើងថ្លៃប្រេងឥន្ធនៈដែលជាទំនិញនាំចូលសុទ្ធសាធ និងបានធ្វើឱ្យទំនិញដទៃទៀតរបស់កម្ពុជាឡើងថ្លៃ (៣)-ការឡើងថ្លៃនៃទំនិញនាំចូលពីប្រទេសថៃ និងការនាំចូល ទំនិញពីប្រទេសដែលមានអតិផរណាខ្ពស់ស្រាប់ ដូចជា វៀត ណាម និងចិន ផងដែរ ។

ទិន្នន័យបម្រែបម្រួលខែលើខែ នៅខែ មេសា ឆ្នាំ ២០១១ នេះ បានបង្ហាញថា ក្នុងចំណោមថ្លៃទំនិញទាំង ១២ ក្រុម មាន ១០ក្រុមបានកើនឡើង និង ២ក្រុម បានថយចុះ ។ ក្រុមទំនិញដែលបានឡើងថ្លៃមានក្រុមដឹកជញ្ជូន ២,៣% ក្រុមម្ហូបអាហារនិង ភេសជ្ជៈមិនមានជាតិស្រវឹង ១,២% ក្រុមផ្ទះ សម្បែង/ទឹក/អគ្គិសនី/ឧស្ម័ន/និងឥន្ធនៈដទៃទៀត ០,៩% ក្រុម ទំនិញនិងសេវាផ្សេងៗ ០,៨% ក្រុមភោជនីយដ្ឋាន ០,៦% ក្រុមគ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់ក្នុងគ្រួសារ និងការថែទាំ ផ្ទះជាប្រចាំ ០,៤% ក្រុមសុខាភិបាល ០,៣% ក្រុមការសិក្សា ០,៣% ក្រុមភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ ០,២% និង ក្រុមសម្លៀកបំពាក់ និងស្បែកជើង ០,២% ។ ចំណែកឯ ក្រុមទំនិញដែលចុះថ្លៃ រួមមានក្រុមគមនាគមន៍ ០,៤% និង ក្រុមការកម្សាន្តនិងវប្បធម៌ ០,១% ។

## ២- អតិផរណាប្រចាំឆ្នាំ

ផ្អែកតាមទិន្នន័យបម្រែបម្រួលឆ្នាំលើឆ្នាំ ក្រាហ្វខាងក្រោម-ឆ្វេងបានបង្ហាញថា អត្រាអតិផរណាឆ្នាំលើឆ្នាំបានកើនឡើងជាបន្តបន្ទាប់ ក្នុងអំឡុង ៤ខែដើមឆ្នាំនេះ ប៉ុន្តែស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបាន ទោះបីជានិន្នាការនៅចុងខែមេសានេះ បានបង្ហាញនូវកំណើនខ្ពស់ដល់កម្រិត ៥,២% ក៏ដោយ ។ បើពិនិត្យមើលអតិផរណាប្រចាំឆ្នាំនៅខែមេសាដូចគ្នា ក្នុងរយៈកាល ៥ឆ្នាំចុងក្រោយវិញ (*ដូចក្នុងក្រាហ្វខាងក្រោម-ស្តាំ*) ឃើញថាស្ថានភាពអតិផរណានៅក្នុងឆ្នាំ២០១១ នេះ មានកម្រិតប្រហាក់ប្រហែលនឹងឆ្នាំ២០១០ និង២០០៧ ប៉ុន្តែទាបជាងខែមេសាដូចគ្នាឆ្នាំ២០០៨ ដែលជាឆ្នាំមានអត្រាកំណើនខ្ពស់ខ្លាំង ហើយខ្ពស់ជាងឆ្នាំ២០០៩ ដែលជាឆ្នាំមានអត្រាអតិផរណាទាបដល់កម្រិតអវិជ្ជមានជាច្រើនខែផងដែរ ។



Figure 20: CPI- (MoM & YoY % CHANGE)



Figure 21: CPI - (YOY % CHANGE)

| Contribution (YOY%) | Feb-11 | Mar-11 | Apr-11 |
|---|---|---|---|
| All Items | 3.8 | 3.8 | 5.2 |
| Food & N A B | 1.7 | 1.8 | 2.6 |
| Transportation | 0.7 | 0.6 | 0.9 |
| Housing W E. | 0.6 | 0.5 | 0.7 |
| Restaurants | 0.4 | 0.4 | 0.5 |
| Health | 0.1 | 0.1 | 0.1 |
| Others | 0.2 | 0.3 | 0.3 |

កត្តាដែលបានរួមចំណែកក្នុងអតិផរណារួមប្រចាំឆ្នាំនៅខែមេសា ឆ្នាំ២០១១ ដែលស្មើនឹង ៥,២% គឺ ១/- ក្រុម ម្ហូបអាហារ និងភេសជ្ជៈពុំមានជាតិស្រវឹង ២,៦% *(ត្រូវ នឹងសមាមាត្រ ៤៨,៨% នៃអត្រាអតិផរណាប្រចាំឆ្នាំ)* ក្រុមដឹកជញ្ជូន ០,៩% *(ត្រូវនឹងសមាមាត្រ ១៧,៨%)* ២/- ក្រុមផ្ទះសម្បែង/ទឹក/អគ្គិសនី/ឧស្ម័ន និងឥន្ធនៈដទៃ ទៀត ០,៧% *(ត្រូវនឹងសមាមាត្រ ១៤,២% )* ៣/- ក្រុមភោជនីយដ្ឋាន ០,៥% *(ត្រូវនឹងសមាមាត្រ ៩,១% )* និង ៥/- ក្រុមសុខាភិបាល *០,១% (ត្រូវនឹងសមាមាត្រ ១,១% )*។ ដោយឡែក មុខទំនិញ ៧ ក្រុមទៀតដែលនៅសល់បាន ចូលរួមចំណែក ០,៣% ប៉ុណ្ណោះ *(ត្រូវនឹងសមាមាត្រ ៥,៧% នៃអត្រាអតិផរណាប្រចាំឆ្នាំ )*។

ទន្ទឹមនោះ ខណៈដែលអតិផរណារួមមានអត្រា ៥,២% ក្នុងខែមេសានេះ អតិផរណាឆ្នាំលើឆ្នាំមិនគិតថ្លៃទំនិញក្រុមម្ហូបអាហារ និងមិនគិតថ្លៃទំនិញនិងសេវាពាក់ព័ន្ធនឹងថ្លៃប្រេងឥន្ធនៈដែលបញ្ចូលទាំងថ្លៃសេវាក្រុមដឹកជញ្ជូន មានអត្រា ៤,៥% និង ៤,៨% រៀងគ្នា ពោលគឺទាបជាងអតិផរណារួម ។ ទិន្នន័យនេះបង្ហាញថា ថ្លៃម្ហូបអាហារនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈជាកត្តាសំខាន់ក្នុងការជំរុញ ឱ្យអតិផរណារួមកាន់តែមានកម្រិតខ្ពស់ឡើងនាខែ មេសានេះ ។ ម្យ៉ាងទៀត អត្រាអតិផរណាមិនរាប់បញ្ចូលទាំងថ្លៃម្ហូបអាហារ និងថ្លៃទំនិញនិងសេវាពាក់ព័ន្ធនឹងថ្លៃប្រេង ឥន្ធនៈរួមគ្នា មានអត្រាត្រឹម ២,៨% បានបង្ហាញថា ទំនិញជាទូទៅផ្សេងៗទៀត ក្រៅពី ២ក្រុម ខាងលើបានឡើងថ្លៃបន្តិចបន្តួច ប៉ុន្តែទំនិញទាំងនោះបានឡើងថ្លៃ ខ្ពស់ជាងខែមករា ១,១% កុម្ភៈ ១,៨% និងមីនា ១,៩% នៅឆ្នាំ២០១១ ។ ទាំងនេះអាចសន្និដ្ឋានបានថា តម្រូវការក្នុងស្រុករបស់អ្នកប្រើប្រាស់មានការកើនឡើងលឿនជាងការផ្គត់ផ្គង់ ហើយនិន្នាការអតិផរណានៅដំណាច់ឆ្នាំ អាចមានកម្រិតខ្ពស់ជាង ៥% ។



Figure 22: Inflation selected group YOY % change

## ខ/- កត្តាដែលមានឥទ្ធិពលលើអតិផរណា

### ១- កត្តាថ្លៃម្ហូបអាហារនិងប្រេងឥន្ធនៈ

នៅដើមឆ្នាំ២០១១ នេះ ថ្លៃម្ហូបអាហារពិភពលោកបានកើនឡើងគួរឱ្យកត់សម្គាល់ ។ បើយើងប្រៀបធៀបនឹងឆ្នាំ២០០៨ ជាឆ្នាំដែលពិភពលោកជួបប្រទះ នឹងសម្ពាធអតិផរណាខ្ពស់ជាងគេប្រមាណ ៦% ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ ថ្លៃម្ហូបអាហារនៅដើម ឆ្នាំ២០១១ នេះ មានកម្រិតខ្ពស់ជាងនៅក្នុងឆ្នាំ២០០៨ ទៅទៀត ។ នេះជាក្តីព្រួយបារម្ភមួយដែលកំណើនថ្លៃម្ហូបអាហារពិភពលោក នឹងធ្វើឱ្យថ្លៃម្ហូបអាហារក្នុងស្រុកមានការកើនឡើងផងដែរ។

Figure 23: FAO Food Price Index




បញ្ហាអស្ថិរភាពផ្នែកនយោបាយនៃប្រទេសនាំចេញប្រេងធំៗមួយចំនួន ដូចជា នីស្សេរីយ៉ា លីប៊ី និងអារ៉ាប៊ីសាវឌីត និងការធ្លាក់ថ្លៃប្រាក់ដុល្លារអាមេរិកបានធ្វើឱ្យថ្លៃប្រេងពិភពលោកកើនឡើងជាបន្តបន្ទាប់ រហូតដល់ ០,៨៤ ដុល្លារអាមេរិក ក្នុង ១លីត្រ ក្នុងខែមេសា ឆ្នាំ២០១១ នេះ ។ ការណ៍នេះបានធ្វើឱ្យថ្លៃប្រេងឥន្ធនៈក្នុងស្រុកមានកំណើនរហូតដល់ ១,២១ ដុល្លារអាមេរិក ក្នុងខែមេសា ឆ្នាំ២០១១ នេះ ។ ថ្លៃប្រេងឥន្ធនៈក្នុងស្រុកមានកំណើនឆ្នាំលើឆ្នាំ បានឡើងថ្លៃប្រមាណ ១៥% ក្នុងខែមេសា ឆ្នាំ២០១១ នេះ ធៀបនឹង ១៨% នាដំណាច់ឆ្នាំ២០១០ និង ២៨% នាខែដូចគ្នា ឆ្នាំ២០១០ រៀងគ្នាផងដែរ ។




## ២- កត្តាអតិផរណានៃប្រទេសជិតខាងនិងទំនិញនាំចូល

នៅក្នុងខែមេសា ឆ្នាំ២០១១ នេះ សម្ពាធអតិផរណាប្រចាំឆ្នាំនៃប្រទេសដៃគូពាណិជ្ជកម្ម និងប្រទេសជិតខាងកម្ពុជាដូចបានបង្ហាញនៅក្នុងក្រាហ្វិច៤ នៅទំព័រទី២ មានល្បឿនកើនឡើងព្រមគ្នា ពោលគឺអតិផរណានៃប្រទេសវៀតណាម ចិន និងថៃ បានកើនឡើងដល់ ១៧,៥% ៥,៣% និង៣,៣% រៀងគ្នា នៅក្នុងខែមេសា ឆ្នាំ២០១១ ពីកម្រិត ១១,៨% ៣% និង៤,៦% នាដំណាច់ឆ្នាំ២០១០ ។ នេះជាក្តីបារម្ភមួយថែមទៀត ក្រៅពីកំណើនថ្លៃប្រេងនិងថ្លៃម្ហូបអាហារ ដែលអាចបណ្តាលឱ្យអតិផរណាប្រទេសកម្ពុជាមានសន្ទុះកើនឡើងនាពេលខ្លីខាងមុខ ។